

ឌីជេអូ
អប់រំ
សុខភាព



មុខវិជ្ជាអប់រំសុខភាព
ថ្នាក់ទី៩

សមាសភាគទី៣ ៖ សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ

ជំពូកទី២ ៖ សុខភាពផ្លូវភេទ

មេរៀនទី៣ ៖ **ការជួញដូរផ្លូវភេទ**

បង្រៀនដោយ ៖ អ្នកគ្រូ ឡុង គីមណា

សប្តាហ៍មុននៅម៉ោងអប់រំសុខភាព
តើប្អូនបានរៀនមេរៀនអ្វី?
មេរៀន ចំណង់ផ្លូវភេទ

រំឭកមេរៀន

តើប្រយោគខាងក្រោមមួយណាដែលមិនមែនជាកត្តាជំរុញឱ្យមានចំណង់ផ្លូវភេទ ?

១- ការបង្ហាញអាកប្បកិរិយា ឬអារម្មណ៍ទាក់ទាញរឿងផ្លូវភេទ

២- ការប្រើគ្រឿងញៀន គ្រឿងស្រវឹង

៣- កង្វះឯកជនភាព ដូចជាការរស់នៅប្រមូលផ្តុំក្នុងបន្ទប់តែមួយ ក្នុងក្លឹប ឬខារ៉ាអូខេ

៤- ការអង្គុយរៀនក្បែរគ្នា ធ្វើការជិតគ្នា។

ចម្លើយត្រឹមត្រូវទី៤

ថ្ងៃនេះបងប្អូនៗនឹងបានសិក្សានូវមេរៀនថ្មី ក្នុងសមាសភាពទី៣
សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ
ជំពូកទី២ សុខភាពផ្លូវភេទ
មេរៀនទី៣ ការជួញដូរផ្លូវភេទ

មេរៀនទី៣ : ការជួញដូរផ្លូវភេទ

គោលបំណង៖

- ប្រាប់និយមន័យ "ជួញដូរផ្លូវភេទ"
- រៀបរាប់ពីមូលហេតុ ផលវិបាក និងវិធានការទប់ស្កាត់ការជួញដូរផ្លូវភេទ
- បង្ហាញពីមូលហេតុ ផលវិបាក និងវិធានការទប់ស្កាត់ការជួញដូរផ្លូវភេទ
- បណ្តុះស្មារតីចូលរួមទប់ស្កាត់ការជួញដូរផ្លូវភេទ។

១- និយមន័យ

ប្រទេសកម្ពុជាមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលអនុម័តដោយរដ្ឋសភា កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧។ រាជរដ្ឋាភិបាលបានផ្តល់ទំនុកចិត្តឱ្យក្រសួងអប់រំ យុវជន និងកីឡា ជាស្ថាប័នសម្របសម្រួលនិងដឹកនាំក្រុមការងារបង្ការទប់ស្កាត់ការជួញដូរមនុស្ស។

១- និយមន័យ

ការជួញដូរផ្លូវភេទ ជាបទល្មើសឧក្រិដ្ឋឬមជ្ឈិម និងជាទម្រង់នៃការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ គេសង្កេតឃើញថា ជនរងគ្រោះនៃការជួញដូរភាគច្រើនគឺស្ត្រី និងកុមារ ដែលស្ថិតនៅក្នុងចំណោមក្រុមជនងាយរងគ្រោះបំផុត ហើយពួកគេមិនត្រូវបានយកចិត្តទុកដាក់ពីអ្នកអាណាព្យាបាល ឬអន្តរាគមន៍អំពីបញ្ហានេះឡើយ។

១- និយមន័យ

តើការជួញដូរមានន័យដូចម្តេច?

តើការជួញដូរផ្លូវភេទមានន័យដូចម្តេច?

១- និយមន័យ

ការជួញដូរផ្លូវភេទ គឺជាការលក់ដូរមនុស្ស។

តាមមាត្រា១៣ : និយមន័យនៃអំពើលក់-ដូរមនុស្ស មានន័យថា ប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬទទួលយកដោយខុសច្បាប់នូវការប្រគល់ ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយដោយរាប់បញ្ចូលទាំងសេវានិងមនុស្សផង។

១- និយមន័យ (ត)

បច្ចុប្បន្នមានការជួញដូរផ្លូវភេទ តាមប្រព័ន្ធអនឡាញដែលមានការកេងប្រវ័ញ្ចធ្វើអាជីវកម្មលើស្ត្រីនិងកុមារដោយរងគ្រោះ ដោយសារការអូសទាញពីក្រុមកេងប្រវ័ញ្ចផ្លូវភេទ តាមរយៈការផ្សព្វផ្សាយរឿងនិងរូបភាពអាសអាភាសជាដើម។
ការប្រើប្រាស់បណ្តាញសង្គមរបស់ក្មេងជំទង់ក្រោមអាយុ១៨ឆ្នាំ ត្រូវមានការគ្រប់គ្រងពីអ្នកអាណាព្យាបាល ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើទំនាក់ទំនងផ្លូវភេទក្នុងក្រុមមនុស្សអាយុដូចគ្នា។

២- មូលហេតុការជួញដូរផ្លូវភេទ

អ្នកគ្រូសូមបែងចែកប្អូនជា៤ក្រុម ដើម្បីពិភាក្សាសំណួរខាងក្រោម ។ ទុករយៈពេលជូន៧នាទីសម្រាប់ពិភាក្សា និងរយៈពេល ៣នាទីសម្រាប់ក្រុមនីមួយៗបកស្រាយចម្លើយ។

២- មូលហេតុការជួញដូរផ្លូវភេទ

សំណួរ៖

១- តើមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមានការជួញដូរផ្លូវភេទ?ចូររៀបរាប់។

២- តើការជួញដូរផ្លូវភេទមានផលវិបាកអ្វីខ្លះដល់បុគ្គល ក្រុមគ្រួសារ និងសង្គម? ចូររៀបរាប់

៣- តើត្រូវមានវិធានការទប់ស្កាត់ការជួញដូរផ្លូវភេទអ្វីខ្លះ?ចូររៀបរាប់។

២- មូលហេតុការជួញដូរផ្លូវភេទ (ត)

មូលហេតុការជួញដូរផ្លូវភេទ៖

- ដោយសារជីវភាពក្រីក្រ
- ស្វែងរកការងារធ្វើ
- ការកើនឡើងនៃសម្ភារៈនិយម
- ជម្លោះក្នុងគ្រួសារ ឬគ្រួសារបែកបាក់
- គ្រោះធម្មជាតិ ឬសង្គ្រាម
- ភាពអវិជ្ជា ភាពល្ងង់ខ្លៅ

២- មូលហេតុការជួញដូរផ្លូវភេទ (ត)

- ពុំមានការគិតពិចារណាល្អិតល្អន់
- អំពើហិង្សាក្នុងគ្រួសារ
- ការសេពគ្រឿងញៀន គ្រឿងស្រវឹង
- ការសេពគប់មិត្តមិនល្អ
- ការអូសទាញនិងឆបោក
- ការអនុវត្តច្បាប់នៅធូរលុង

២- មូលហេតុការជួញដូរផ្លូវភេទ (ត)

- អយុត្តិធម៌ក្នុងសង្គម
- ការខូចចិត្ត
- មានវិបត្តិស្នេហា
- គ្មានការងារធ្វើ ឬមុខរបរចិញ្ចឹមជីវិត ។ល។

ការជួញដូរផ្លូវភេទ មានគោលដៅស្វែងរកផលប្រយោជន៍ បំពានផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ស្នុំកូន ឬទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត។

២- មូលហេតុការជួញដូរផ្លូវភេទ (ត)



សកម្មភាពនៃការជួយដូរផ្លូវភេទ

៣- ផលវិបាកការជួញដូរផ្លូវភេទ

ផលវិបាកកើតចេញពីការជួញដូរផ្លូវភេទ

ការជួញដូរមនុស្សអាចមានឥទ្ធិពលលើរាងកាយ ផ្លូវចិត្តរបស់ជនរងគ្រោះនិងផ្លូវចិត្តអ្នកពាក់ព័ន្ធ ហើយវាជះឥទ្ធិពលដល់ដំណើរជីវិតរបស់ជនរងគ្រោះអាចប្រឈមទៅនឹង៖

- អំពើហិង្សា : ពាក្យសម្តី វាយដំ ដែលអាចមានរបួសដល់រាងកាយជនរងគ្រោះ

៣- ផលវិបាកការជួញដូរផ្លូវភេទ (ត)

- ការប៉ះទង្គិចផ្លូវចិត្តនៃការជួញដូរផ្លូវភេទមានដូចជា៖ ជំងឺបាក់ស្បាត ថប់បារម្ភ ធ្លាក់ទឹកចិត្ត និងជំងឺភ្លេចភ្លាំង ដែលត្រូវព្យាបាលរយៈពេលយូរ
- ឆ្លងជំងឺកាមរោគ មេរោគអេដស៍ និងជំងឺដទៃទៀត
- បាត់បង់ការសិក្សា ចំណេះដឹង។

៤- វិធានការទប់ស្កាត់ការជួញដូរផ្លូវភេទ

វិធានការទប់ស្កាត់នៃការជួញដូរផ្លូវភេទ

វិធីសាស្ត្រ ឬមធ្យោបាយក្នុងការរារាំង ឬបង្ការទុកជាមុននូវភាពងងៃគ្រោះនានាឱ្យបានទាន់ពេលវេលា ជាពិសេសអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។ ការជួញដូរផ្លូវភេទអាចការពារ និងទប់ស្កាត់បាន។

ចំណុចដែលចាប់ផ្តើមសំខាន់ៗនោះគឺ៖

៤- វិធានការទប់ស្កាត់ការជួញដូរផ្លូវភេទ(ត)

- ត្រូវផ្តោតលើការបង្កើនការយល់ដឹងរបស់សហគមន៍អំពីការជួញដូរមនុស្ស និងដោះស្រាយការកេងប្រវ័ញ្ចដែលកើតមាន
- លើកកម្ពស់ការយល់ដឹងនិងដាក់បញ្ចូលប្រធានបទការជួញដូរផ្លូវភេទ នៅក្នុងការអប់រំរឿងផ្លូវភេទគ្រប់ជ្រុងជ្រោយក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ
- បង្កើនការស្រាវជ្រាវបន្ថែមដើម្បីវាយតម្លៃកម្មវិធីនិងគោលនយោបាយ ដែលជួយកាត់បន្ថយកត្តាដែលធ្វើឱ្យមនុស្សប្រឈមនឹងគ្រោះថ្នាក់ ដើម្បីជួយទប់ស្កាត់ការជួញដូរផ្លូវភេទនិងជួញដូរមនុស្ស។

៤- វិធានការទប់ស្កាត់ការជួញដូរផ្លូវភេទ (ត)

- យុទ្ធសាស្ត្រផ្អែកលើកស្តុតាង ដែលអាចរកបានល្អបំផុតមានដើម្បី ការពារអំពើហិង្សាដែលពាក់ព័ន្ធនឹងជនរងគ្រោះ ហើយក៏អាចកាត់បន្ថយការជួញដូរផ្លូវភេទផងដែរ។
- ក្នុងពេលជាមួយគ្នានេះដែររដ្ឋាភិបាលនិងសហគមន៍ត្រូវ៖
  - លើកទឹកចិត្តឱ្យមានឥរិយាបថល្អក្នុងទំនាក់ទំនង
  - លើកកម្ពស់និងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព និងប្រកបដោយប្រសិទ្ធភាព

៤- វិធានការចង់ស្គាត់ការជួញដូរផ្លូវភេទ(ត)

- ចូលរួមយ៉ាងសកម្មក្នុងក្រុមប្រឹក្សាយុវជន
- ចែករំលែក ផ្តល់ព័ត៌មាន និងក្លាហានក្នុងការរាយការណ៍ពីការជួញដូរទៅលោកគ្រូ អ្នកគ្រូ ចាស់ទុំ គ្រួសារ អាជ្ញាធរភូមិ ឃុំ ដែលអ្នកទុកចិត្តនិងនៅជិតអ្នក
- បង្កើតនិងបង្កើនជីវភាពក្នុងមូលដ្ឋានតាមរយៈការដាំដុះនិងមុខរបរផ្សេងៗ

៤- វិធានការទប់ស្កាត់ការជួញដូរផ្លូវភេទ(ត)

- កំណត់និងដោះស្រាយភាពងាយរងគ្រោះក្នុងអំឡុងពេលពិនិត្យសុខភាព
- កាត់បន្ថយនូវរាល់អាជីវកម្ម ឬរូបភាពផ្សព្វផ្សាយដែលជំរុញផ្លូវភេទ
- បំបាត់អាជីវកម្មរកផលចំណេញទាំងឡាយណាដែលមានរូបភាពប្រតិបត្តិការទាក់ទងនឹងការជួញដូរមនុស្ស។

៤- ចិធានការធប់ស្ពាត់ការជួញដូរផ្លូវភេទ(ត)

គន្លឹះត្រូវចងចាំ៖

- ការជួញដូរផ្លូវភេទ គឺនៅពេលនរណាម្នាក់ដែលមាន "ភ្នាក់ងារ" ជ្រើសរើសបុគ្គលិក ដឹកជញ្ជូន លក់ឬទិញមនុស្ស ដើម្បីធ្វើអាជីវកម្មផ្លូវភេទ។

ឧទាហរណ៍ តាមរយៈការបង្ខំឱ្យពួកគេលក់ភេទនៅក្នុងប្រទេសរបស់ខ្លួន ឬនៅក្រៅប្រទេស។

៤- វិធានការចៀសវាងការជួញដូរផ្លូវភេទ(ត)

- អ្នកជួញដូរផ្លូវភេទប្រើភាពមិនស្មោះត្រង់ ការបញ្ឆោត និងការក្លែងបន្លំ ជាញឹកញាប់ជាមួយការបំភិតបំភ័យ ការដាក់កំហិត(សន្យាថាផ្តល់ការងារឱ្យធ្វើ)ការគំរាមកំហែងដល់មនុស្ស ឬការជាប់ពន្ធនាគារ និងការបង្ខំកម្លាំងកាយ ដើម្បីទាក់ទាញនិងគ្រប់គ្រងជនរងគ្រោះ
- ក្មេងស្រីនិងស្ត្រីខ្លះត្រូវបានគេលក់ទៅរកការជួញដូរផ្លូវភេទដោយមនុស្សដែលគេស្គាល់និងទុកចិត្តរួមទាំងឪពុកម្តាយ ប្តី សមាជិកគ្រួសារផ្សេងទៀត និងមិត្តប្រុស
- ជារឿយៗការជួញដូរចាប់ផ្តើមជាមួយនឹងការផ្តល់ការងារ។

មេរៀនសង្ខេប

- **ការជួញដូរផ្លូវភេទ** : គឺជាការលក់ដូរមនុស្ស ដោយមានគោលដៅស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ស្ទុះកូន ឬទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត។
- **មូលហេតុការជួញដូរផ្លូវភេទ** : ដោយសារជីវភាពក្រីក្រ ស្វែងរកការងារធ្វើ ការកើនឡើងនៃសម្ភារនិយម ជម្លោះគ្រួសារឬគ្រួសារបែកបាក់ ភាពអវិជ្ជា អំពើហិង្សាក្នុងគ្រួសារ ការសេពគ្រឿងញៀន គ្រឿងស្រវឹង ការសេពគប់មិត្តមិនល្អ ការខូចចិត្ត មានវិបត្តិស្នេហា គ្មានការងារធ្វើ ឬមុខរបរចិញ្ចឹមជីវិត ។ល។

មេរៀនសង្ខេប (ត)

- ផលវិបាកការជួញដូរផ្លូវភេទ : អាចមានឥទ្ធិពលលើរាងកាយ ផ្លូវចិត្តរបស់ជនរងគ្រោះ និងផ្លូវចិត្តនៃអ្នកដែលពាក់ព័ន្ធ។ ការប៉ះទង្គិចផ្លូវចិត្តនៃការជួញដូរផ្លូវភេទ ប្រឈមទៅនឹងការព្យាបាលវិបត្តិផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ និងហានិភ័យខ្ពស់នៃការឆ្លងជំងឺកាមរោគ។
- វិធានការទប់ស្កាត់ការជួញដូរផ្លូវភេទ : មានវិធីសាស្ត្រឬមធ្យោបាយក្នុងការរារាំងឬបង្ការទុកជាមុននូវភាពរងគ្រោះនានាឱ្យបានទាន់ពេលវេលា ដោយបង្កើនការយល់ដឹងរបស់សហគមន៍អំពីការជួញដូរមនុស្សនិងដំណោះស្រាយការកេងប្រវ័ញ្ចដែលកើតមាន។



រឿងយតម្លៃ

ប្រសិនបើអ្នកដឹងថាមានអំពើជួញដូរផ្លូវភេទ ឬជួញដូរមនុស្ស
តើអ្នកត្រូវធ្វើបែបណា?

១- សុំគ្រលំចូលរួមជាមួយទង្វើនោះដែរដើម្បីបានប្រយោជន៍

២- មិនខ្វល់ព្រោះមិនពាក់ព័ន្ធជាមួយក្រុមគ្រួសារខ្លួនផ្ទាល់

៣- រាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរមូលដ្ឋានសុំអន្តរាគមន៍

៤- ដើរទៅប្រាប់អ្នកទាំងនោះថាពួកគេធ្វើនេះគឺខុសច្បាប់។

ចម្លើយត្រឹមត្រូវទី៣

វេទាយតង្ស (ត)

តើតរិយាបថមួយណាដែលយុវជនមិនគួរធ្វើ?

១- ចូលរួមផ្សព្វផ្សាយពីច្បាប់ផ្សេងៗនិងបង្កើនការយល់ដឹងអំពីការជួញដូរមនុស្ស

២- បង្កើតនិងបង្កើនជីវភាពក្នុងមូលដ្ឋានតាមរយៈការដាំដុះបង្កើតមុខរបរនិងដោះស្រាយទីផ្សារកសិផល

៣- ចូលរួមដោះស្រាយការកេងប្រវ័ញ្ចគ្រប់រូបភាពដែលកើតមានជាមួយអាជ្ញាធរ

៤- មិនចាប់អារម្មណ៍ពេលដឹងថាមានការជួយដូរមនុស្សនៅសហគមន៍របស់ខ្លួន

៥- ចូលរួមក្នុងលើកកម្ពស់ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព។

លំហាត់

កិច្ចការផ្ទះ

ចូរប្អូនៗស្រាវជ្រាវពីគ្រោះថ្នាក់នៃការប្រើប្រាស់បណ្តាញសង្គម
ដោយសួរព័ត៌មានពីឪពុកម្តាយ បងៗ សម្រាប់រៀននៅម៉ោងអប់រំសុខភាព
សប្តាហ៍ក្រោយ។

បណ្តាំផ្ញើ

ចូរប្អូនៗទាំងអស់គ្នា ចូលរួមទប់ស្កាត់ការជួញដូរផ្លូវភេទ។

សូមអរគុណ !